ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥១ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការចំរុះ ដើម្បីសិក្សាបន្ថែមអំពីរបៀបចាក់លុបផ្ទៃដីបឹងស្នាយ ខេត្តកំពង់ចាម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ ១**: បង្កើតគណៈកម្មការចំរុះ ដើម្បីសិក្សាអំពីរបៀបចាក់លុបផ្ទៃដីបឹងស្នាយខេត្តកំពង់ចាម ដែលមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **អ៊ឹម ឈុនលឹម** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២-ឯកឧត្តម **ជា សុផារ៉ា** | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៣-ឯកឧត្តម **ហ៊ុន ណេង** | អភិបាលខេត្តកំពង់ចាម | អនុប្រធានអចិន្ត្រៃយ៍ |

www.pheakdeylaw.com

| | | | |
|---|---|---|---|
| ៤-ឯកឧត្តម | ម៉ុន អ៊ិុយ | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥-ឯកឧត្តម | អ៊ុក រ៉ាប៊ុន | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦-ឯកឧត្តម | អ៊ិត ប្រាំង | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៧-ឯកឧត្តម | សំ សារិត | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៨-ឯកឧត្តម | ស្ទួន ហោង | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៩-ឯកឧត្តម | នូ តៀង | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១០-ឯកឧត្តម | ឆា ជុប | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |

**ប្រការ ២ :** គណៈកម្មការចំរុះនេះ មានភារកិច្ចសិក្សាបន្ថែមអំពីរបៀបចាក់លុបផ្ទៃដីបឹងស្នាយ ដោយធានាដោះស្រាយការបាត់ផ្លូវរងទឹកភ្លៀង ទីតាំងប្រភពដីដែលត្រូវបូមចាក់លុបបឹង និងអំពីការទូទាត់ចំណាយជាក់ស្តែង ដើម្បីលើកសំណើជូនរាជរដ្ឋាភិបាលពិនិត្យសម្រេច ។

**ប្រការ ៣ :** អនុប្រធាន និងសមាជិកគណៈកម្មការចំរុះនេះ ត្រូវចូលរួមប្រជុំ និងចូលរួមបំពេញភារកិច្ចតាមការអញ្ជើញ និងតាមការណែនាំរបស់ប្រធាន ។

**ប្រការ ៤ :** គណៈកម្មការចំរុះនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ក្នុងករណីចាំបាច់គណៈកម្មការចំរុះនេះ អាចបង្កើតអនុគណៈកម្មការ ឬក្រុមការងារជំនាញដើម្បីជួយក្នុងកិច្ចការសិក្សាបន្ថែមនេះ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៥*
- *ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com